មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

គម្រោង
និទ្ទាការគេចនិងអត្តសញ្ញាណយេនឌ័រ (សូជី)

Address:
#798, St. 99, Sangkat Boeung Trabek, Khan Chamkamom, PP.
Email: info@cchrcambodia.org , Website: www.cchrcambodia.org, www.sithi.org
Tel : (855) 23 72 69 01
Fax : (855) 23 72 69 02

ទិដ្ឋភាពទូទៅនៃស្ថានភាពស៊ីដៅកម្ពុជា

- អ្នកស្រលាញ់ភេទដូចគ្នាប្រឈមនឹងការរើសអើងក្នុងវិស័យជាច្រើនក្នុងសង្គមកម្ពុជារួមទាំងក្រុមគ្រួសារ សហគមន៍ វិស័យការងារ អប់រំ ការថែរសុខភាព និងប្រព័ន្ធផ្សព្វផ្សាយ។
- សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាមិនត្រូវបានទទួលស្គាល់ដោយច្បាប់ជាក់លាក់ណាមួយ ឬនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រមិនត្រូវបានបញ្ចាក់ជាមូលដ្ឋានហាមឃាត់ ចំពោះការរើសអើង។
- ច្បាប់ជាតិដែលបង្កប់អត្ថន័យការរើសអើងនោះគឺត្រង់អ្នកមានភេទដូចគ្នាមិនអាចរៀបការនឹងគ្នាបានទេហើយអ្នកស្រលាញ់ភេទដូចគ្នាតែងត្រូវអាជ្ញាធរធ្វើទុក្ខបុកម្នេញ។

ទិដ្ឋភាពទូទៅរបស់គម្រោង - គោលបំណងគម្រោង

❖ គោលបំណង

គោលបំណងសំខាន់របស់គម្រោងសូជីគឺដើម្បីធ្វើអោយប្រសើរឡើងនូវការគោរពនិងការយល់ដឹងអំពីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជាក្នុងគោលបំណងដើម្បីកាត់បន្ថយអំពើហិង្សា ការរើសអើងនិងការរំលោភបំពានសិទ្ធិមនុស្សដែលអ្នកស្រលាញ់ភេទដូចគ្នាទទួលរងជាប្រចាំនៅទូទាំងប្រទេសកម្ពុជា។

❖ យុទ្ធវិធី

ការចងបណ្តាញ ៖ តាមរយៈការភ្ជាប់ទំនាក់ទំនង បុគ្គល សហគមន៍ អ្នកការពារសិទ្ធិមនុស្ស អង្គការសហគមន៍ អង្គការតាមវិស័យការងារ វិស័យឯកជននិងអ្នកទទួលផលផ្សេងទៀត។

ទិដ្ឋភាពទូទៅរបស់គម្រោង - គោលបំណងគម្រោង

ការផ្តល់អំណាច ៖ ផ្តល់ជាសកម្មភាពកសាងសមត្ថភាព និងផ្សេរជំនាញនិងចំណេះដឹងដើម្បីធ្វើឲ្យប្រសើរឡើងនូវការគោរពសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅទូទាំងប្រទេសកម្ពុជា។

ការតស៊ូមតិ ៖ ធ្វើការស្រាវជ្រាវ និងវិភាគពីស្ថានភាពបច្ចុប្បន្នរបស់សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា និងតស៊ូមតិដើម្បីឲ្យមានការយល់ដឹងពីសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា។

ទិដ្ឋភាពទូទៅរបស់គម្រោង - សកម្មភាពគម្រោង

ការចងបណ្តាញ ៖

- គាំទ្រដល់បណ្តាញអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា ដែលជា បុគ្គល សហគមន៍ អង្គការតាមមូលដ្ឋាន សកម្មជន និង អង្គការមិនមែនរដ្ឋាភិបាល
- ផ្តល់ព័ត៌មាន និងឯកសារផ្សេងៗ សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា ក៏ដូចជា អ្នកដែលមានចំណាប់អារម្មណ៍ទៅលើសូជី នៅលើគេហ ទំព័រស្តីអំពី ឥន្ធនូខ្មែរ
- ចុះផ្ទាល់តាមមូលដ្ឋានដើម្បីប្រមូលព័ត៌មានពីសហគមន៍អ្នក ស្រលាញ់ភេទដូចគ្នា និងសកម្មជនអ្នកស្រលាញ់ភេទដូចគ្នា។

ទិដ្ឋភាពទូទៅរបស់គម្រោង - សកម្មភាពគម្រោង

ការផ្តល់អំណាច ៖

ផ្តល់ជូននូវសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលទៅដល់អ្នកស្រលាញ់ភេទដូចគ្នា សកម្មជន សហគមន៍ អង្គការតាមមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលក្នុងគោលបំណងផ្តល់ចំណេះដឹង និងជំនាញដើម្បីពង្រឹងអំណាចក្រុមទាំងនេះឲ្យចេះតស៊ូមតិដើម្បីមានការទទួលស្គាល់ពីសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា។

ទិដ្ឋភាពទូទៅរបស់គម្រោង - សកម្មភាពគម្រោង

ការតស៊ូមតិ ៖

- តាមដានព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយ និងអត្ថបទនានាដែលទាក់ទងទៅនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ
- បោះផ្សាយកំណត់ត្រាសង្ខេប របាយការណ៍ សេចក្តីថ្លែងការណ៍ សេចក្តីប្រកាសព័ត៌មាន និងគោលនយោបាយសង្ខេបទាក់ទងនឹង សូជី
- រៀបចំការដាក់ពិភាក្សាកម្មវិធីវិទ្យុនៅក្នុង"កម្មវិធីវិទ្យុសិទ្ធិមនុស្សកម្ពុជា" របស់ ម.ស.ម.ក
- ផ្តល់ការគាំទ្រជាថវិកា និងចូលរួមនៅក្នុងទិវាសប្តាហ៍អ្នកស្រលាញ់ភេទដូចគ្នា ទិវាប្រឆាំងនិងអ្នកស្រលាញ់ភេទដូចគ្នា និងទិវាសិទ្ធិមនុស្សអន្តរជាតិ
- ផ្តល់ការគាំទ្រផ្នែកថវិកាក្នុងការផលិតភាពយន្តឯកសារ និងការដាក់បញ្ចាំងឯកសារ។

ក្រុមគោលដៅ


ក្រុមគោលដៅ
អង្គការមិនមែនរដ្ឋាភិបាល
អង្គការតាមមូលដ្ឋាន
អ្នកស្រលាញ់ភេទដូចគ្នាដែលជាបុគ្គល
សហគមន៍អ្នកស្រលាញ់ភេទដូចគ្នា
រដ្ឋាភិបាល
សកម្មជនអ្នកស្រលាញ់ភេទដូចគ្នា

អរគុណសម្រាប់ការយកចិត្តទុកដាក់!

សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងតាមរយៈ ៖

(+៨៥៥) ២៣ ៧២៦ ៩០១ ឬ info@cchrcambodia.org

ឬ លោក នួន ស៊ីដារ៉ា អ្នកសម្របសម្រួលគម្រោងនិន្នាការកេទ និងអត្តសញ្ញាណយេនឌ័រ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

(+៨៥៥) ៩៧ ៩៦៦ ៦៥៦៦

ឬ sidara.nuon@cchrcambodia.org